## សំណួរដែលគេច្រើនសួរញឹកញាប់

**តើមានព័ត៌មានអ្វីខ្លះដែលខ្ញុំអាចទទួលបានអំពីអ្នកនៅក្រោមអាផ្សាសង្កេត?**

- លក្ខខណ្ឌពីការនៅក្រោមអាផ្សាសង្កេ
- ការល្មើសធ្ងន់ចំពោះលក្ខខណ្ឌអាផ្សាសង្កេ
- ដីកា

ព័ត៌មានផ្ទាល់ខ្លួនអំពីអ្នកនៅក្រោមអាផ្សាសង្កេតមិនអាចត្រូវគេចែកចាយបានឡើយ

**ហេតុអ្វីបានតុលាការត្រួតពិនិត្យខុសគ្នាពីតុលាការដែលអ្នកនៅក្រោមអាផ្សាសង្កេតត្រូវបានគេផ្តន្ទាទោស?**

សេវាកម្មអាផ្សាសង្កេតរដ្ឋ MA ត្រួតពិនិត្យអ្នកដែលស្ថិតក្រោមអាផ្សាសង្កេតក្នុងសហគមន៍ដែលពួកគេរស់នៅ។ បើសិនជាអ្នកស្ថិតក្រោមអាផ្សាសង្កេតផ្លាស់ទៅនៅក្នុងសហគមន៍មួយផ្សេងទៀត ការតាមសង្កេតលើពួកគេអាចត្រូវគេផ្ទេរទៅតុលាការ និងមន្ត្រីអាផ្សាសង្កេតមួយទៀតដែរ។

**តើខ្ញុំនឹងត្រូវគេជូនដំណឹងដែរឬទេ ប្រសិនបើចំនួនប្រាក់សំណងមានការផ្លាស់ប្តូរ?**

ត្រូវហើយ, មន្ត្រីទទួលខុសត្រូវអាផ្សាសង្កេត ឬអ្នកសម្របសម្រួលសេវាជនរងគ្រោះនឹងប្រាប់លោក-អ្នកឱ្យដឹង បើសិនជាមានការផ្លាស់ប្តូរណាមួយ។ ក្នុងនាមជាជនរងគ្រោះនៃអំពើឧក្រិដ្ឋ លោក-អ្នកមានសិទ្ធិជំរាបទៅចៅក្រមនូវអ្វីដែលអ្នកយល់ឃើញពីការផ្លាស់ប្តូរណាមួយ។

**តើខ្ញុំទទួលប្រាក់សំណងដោយរបៀបណា?**

លោក-អ្នកនឹងទទួលសែកមួយពីការិយាល័យក្រឡាបញ្ជី។

## ធនធានទូទាំងរដ្ឋ

**Massachusetts Probation Service**
**Victim Services Unit**
(សេវាកម្មអាផ្សាសង្កេតរដ្ឋម៉ាស្សាជូសេត្ស៍
អង្គភាពសេវាកម្មជនរងគ្រោះ)
617-727-5300

**Massachusetts Office for Victim Assistance**
**Victim and Witness Assistance Board**
(ការិយាល័យរដ្ឋម៉ាស្សាជូសេត្ស៍សម្រាប់ជំនួយជនរងគ្រោះ
គណៈកម្មការជួយដល់ជនរងគ្រោះនិងសាក្សី)
617-586-1340

**Victim Compensation and Assistance Division**
**Office of the Attorney General**
(អង្គភាពផ្នែកជំនួយនិងសំណងដល់ជនរងគ្រោះ
ការិយាល័យអគ្គមេធាវី)
617-727-2200, លេខបន្ត 2160

**Department of Criminal Justice Information Services (DCJIS) – Victim Services Unit**
(សេវាកម្មព័ត៌មាននាយកដ្ឋានយុត្តិធម៌ព្រហ្មទណ្ឌ (DCJIS) –
អង្គភាពសេវាកម្មជនរងគ្រោះ)
617-660-4690 or 617-660-4606 (TTY)

**Department of Youth Services (DYS)**
**Victim Services Unit**
(នាយកដ្ឋានសេវាកម្មយុវជន (DYS)
អង្គភាពសេវាកម្មជនរងគ្រោះ)
617-960-3290

**Massachusetts Department of Correction (DOC)**
**Victim Services Unit**
(នាយកដ្ឋានពន្ធនាគាររដ្ឋម៉ាស្សាជូសេត្ស៍ (DOC)
អង្គភាពសេវាកម្មជនរងគ្រោះ)
508-422-1939 or toll free, 866-684-2846
(866) 6VICTIM

**Massachusetts Parole Board**
**Victim Services Unit** (គណៈកម្មការដោះលែងដោយមានលក្ខខណ្ឌនៃរដ្ឋម៉ាស្សាជូសេត្ស៍
អង្គភាពសេវាកម្មជនរងគ្រោះ)
508-650-4500

**Sex Offender Registry Board (SORB)**
**Victim Services Unit**
(គណៈកម្មការកត់ត្រាពិរុទ្ធិករផ្លូវភេទ (**SORB**)
អង្គភាពសេវាកម្មជនរងគ្រោះ)
**978-740-6440** ឬដោយឥតគិតថ្លៃ
**(800) 93MEGAN (800-936-3426)**

# Massachusetts Probation Service
## (សេវាកម្មអាផ្សាសង្កេតរដ្ឋម៉ាស្សាជូសេត្ស៍)

# Victim Services Unit
(អង្គភាពសេវាកម្មជនរងគ្រោះ)

1 Ashburton Place, Room 405
Boston, MA 02108

www.mass.gov/probation
617-727-5300

# អង្គភាពសេវាកម្មជនរងគ្រោះ

អង្គភាពសេវាកម្មជនរងគ្រោះ(VSU) របស់ស្ថាប័នអាជ្ញាសង្កេតរដ្ឋម៉ាស្សាជូសេត្ស៍ធ្វើឱ្យប្រាកដថា ជនរងគ្រោះ និងអ្នករស់រានមានជីវិតពីអំពើឧក្រិដ្ឋដឹងពីសិទ្ធិរបស់ពួកគេ និងទទួលបានការជួយដែលពួកគេត្រូវការ។

VSU នឹងឆ្លើយសំនួរនានារបស់លោក-អ្នក និងជួយជាមួយ៖

- គ្រោងការសុវត្ថិភាព
- ការណែនាំក្នុងការរកធនធានផ្សេងៗ
- ការជួយធ្វើអន្តរាគមន៍ពេលមានវិបត្តិ
- ពេលឡើងតុលាការ
- ការសម្របសម្រួលសេវាកម្មសហគមន៍

គម្រោងនេះត្រូវបានគាំទ្រដោយការិយាល័យរបស់រដ្ឋម៉ាស្សាជូសេត្ស៍សម្រាប់ជួយដល់ជនរងគ្រោះតាមរយៈជំនួយតាមច្បាប់ជួយដល់ជនរងគ្រោះដោយអំពើឧក្រិដ្ឋឆ្នាំ 1984 (VOCA) ពីការិយាល័យជនរងគ្រោះនៃអំពើឧក្រិដ្ឋ, ការិយាល័យកម្មវិធីយុត្តិធម៌, ក្រសួងយុត្តិធម៌សហរដ្ឋអាមេរិក។

# ដឹងពីសិទ្ធិរបស់លោក-អ្នក

ច្បាប់សិទ្ធិជនរងគ្រោះនៃរដ្ឋម៉ាស្សាជូសេត្ស៍ផ្តល់ឱ្យជនរងគ្រោះ និងអ្នករួចផុតពីអំពើឧក្រិដ្ឋមានតួនាទីដ៏មានអត្ថន័យមួយនៅក្នុងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ។*

VSU ជួយទាក់ទងនឹងសិទ្ធិរបស់លោក-អ្នកដើម្បី:

- រកឈ្មោះនិងព័ត៌មានទំនាក់ទំនងរបស់មន្ត្រីអាជ្ញាសង្កេតដែលជាអ្នកត្រួតពិនិត្យបុគ្គលស្ថិតក្រោមអាជ្ញាសង្កេត
- ទៅយកកាលវិភាគពីការបង់សំណង
- យល់ដឹងពីការផ្លាស់ប្តូរនានាទាក់ទងបញ្ជាប្រាក់សំណង
- និយាយនៅក្នុងសវនាការណាដែលប្រាក់សំណងអាចត្រូវបានគេកែប្រែផ្លាស់ប្តូរ
- និយាយជាមួយមន្ត្រីអាជ្ញាសង្កេតមុនពេលប្រគល់របាយការណ៍បច្ចុប្បន្ន

* សម្រាប់ការចុះបញ្ជីឱ្យបានពិស្តារនៃច្បាប់ស្តីពីសិទ្ធិជនរងគ្រោះ សូមមើលនៅ M.G.L. ជំពូក 258B

# សំណួរដែលគេច្រើនសួរញឹកញាប់

## តើអាជ្ញាសង្កេតជាអ្វី?

អាជ្ញាសង្កេតគឺជាការដាក់ទណ្ឌកម្មដោយតុលាការ។ ខណៈដែលស្ថិតក្រោមអាជ្ញាសង្កេត ពិរុទ្ធិករត្រូវតែអនុវត្តតាមវិធានជាក់លាក់ដែលគេហៅថាលក្ខខណ្ឌ។ ពិរុទ្ធិករត្រូវបានគេចាត់តាំងមន្ត្រីអាជ្ញាសង្កេតឱ្យតាមមើល ថាតើពិរុទ្ធិករនោះធ្វើតាមបញ្ជារបស់តុលាការឬអត់។ ខណៈនៅក្រោមអាជ្ញាសង្កេត ពិរុទ្ធិករត្រូវបានគេហៅថាបុគ្គលស្ថិតក្រោមអាជ្ញាសង្កេត។

## តើមានអ្វីកើតឡើងប្រសិនបើអ្នកស្ថិតក្រោមអាជ្ញាសង្កេតមិនគោរពតាមបទបញ្ជារបស់តុលាការ?

នៅពេលអ្នកស្ថិតក្រោមអាជ្ញាសង្កេតមិនគោរពតាមបញ្ជារបស់តុលាការមន្ត្រីអាជ្ញាសង្កេតរបស់ពួកគេអាចជូនដំណឹងដល់ចៅក្រម និងស្នើសុំឱ្យមានសវនាការដែលហៅថា“នីតិវិធីការនៃការល្មើសលក្ខខណ្ឌអាជ្ញាសង្កេត”។

## តើអ្វីទៅជាដំណើរនីតិវិធីនៃការល្មើសលក្ខខណ្ឌអាជ្ញាសង្កេត?

“ដំណើរនីតិវិធីនៃការល្មើសលក្ខខណ្ឌអាជ្ញាសង្កេត” គឺជាសវនាការក្នុងតុលាការ។ នៅក្នុងសវនាការ មន្ត្រីអាជ្ញាសង្កេតផ្តល់ភស្តុតាងដើម្បីបង្ហាញថាមានការល្មើសលក្ខខណ្ឌអាជ្ញាសង្កេតមែន។ ប្រសិនបើចៅក្រមសម្រេចថា អ្នកស្ថិតក្រោមអាជ្ញាសង្កេតបានល្មើសលក្ខខណ្ឌ នោះចៅក្រមអាចផ្លាស់ប្តូរវិធានការ ឬប្តូរលក្ខខណ្ឌ ឬបញ្ជាអោយជាប់ពន្ធនាគារ។

## បើសិនជាពិរុទ្ធិករត្រូវគេបញ្ជូនទៅពន្ធនាគារដោយសារតែល្មើសដំណើរនីតិវិធីអាជ្ញាសង្កេត តើខ្ញុំនឹងត្រូវគេជូនដំណឹងពីការដោះលែងពួកគេឬអត់?

ប្រាកដណាស់។ ចូរទាក់ទងអង្គភាពសេវាកម្មជនរងគ្រោះ។ ពួកយើងនឹងជួយលោក-អ្នកឱ្យគេទទួលស្គាល់ និងបានទទួលការជូនដំណឹងពីការដោះលែង។